# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំឱ្យអនុវត្តនីតិវិធីបង្គាប់ឱ្យចេញសេចក្តីសម្រេចប្រមូលសេចក្តីប្រកាសអំពីការចេញដីកាបង្គាប់ឱ្យសង

**ម្ចាស់បំណុល**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង[1]។

**អ្នកតំណាងដោយអាណត្តិ**

ឈ្មោះ៖លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យ ៖ .................................

ឈ្មោះការិយាល័យមេធាវី/ក្រុមមេធាវី/ក្រុមហ៊ុនមេធាវី ៖ ..........................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................[2]

**កូនបំណុល**

ឈ្មោះ ៖ Y

អាសយដ្ឋាន ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តបាត់ដំបង។

---

[1] យោងមាត្រា ៥៦៤ , ចំណុច ក កថាខណ្ឌទី ១ និង ចំណុច ក កថាខណ្ឌទី ២ មាត្រា ៣៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[2] យោងមាត្រា ៥៣៩, មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីទីកន្លែងបញ្ជូន មិនមែនជាករណីយកិច្ចទេ។ ប្រសិនបើមិនសរសេរទីកន្លែងបញ្ជូន នោះការបញ្ជូន នឹងបញ្ជូនទៅអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍។ ហេតុដូច្នេះ ករណីដែលអ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុលមានបំណងចង់ឱ្យធ្វើការបញ្ជូនទៅទីកន្លែងក្រៅពីអាសយដ្ឋានរបស់ម្ចាស់បំណុល ជាអាទិ៍ ចាំបាច់ត្រូវសរសេរទីកន្លែងបញ្ជូនជាលាយលក្ខណ៍អក្សរដូចជានៅក្នុងពាក្យសុំ ជាអាទិ៍។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ ប្រធានសាលាដំបូងរាជធានីភ្នំពេញ[3]**

**លិខិតអនុវត្តៈ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន លេខ ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ**

ម្ចាស់បំណុល ទាមទារឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្ន តាមរបៀបនៃការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន ចំពោះអចលនវត្ថុដែលមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដែលជាការអនុវត្តតាមការបង្ខំដោយផ្ទាល់ ផ្អែកតាមដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[4]លេខ០០ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។ [5]

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តម/លោកជំទាវប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម/លោកជំទាវប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តបាត់ដំបង, ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០២០

**អ្នកតំណាងដោយអាណត្តិ**

ឯកសារភ្ជាប់

១-ឯកសារថតចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ១ច្បាប់

២-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ១ច្បាប់

P

---

[3] ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ តុលាការដែលចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ (កថាខណ្ឌទី ២ មាត្រា ៥៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញ មាន សមត្ថកិច្ចជាតុលាការអនុវត្តរឹបអូសជាបណ្តោះអាសន្ន។

[4] យោងមាត្រា ៥៦៤ និង ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] យោងមាត្រា ៥៦៤, ចំណុច គ និង ចំណុច ឃ កថាខណ្ឌទី ២ មាត្រា ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធអំពីវត្ថុ

"ទីតាំងដី" ផ្លូវលេខ ០០ ភូមិ...... សង្កាត់.......ខណ្ឌ.........រាជធានីភ្នំពេញ

"លេខ/លេខឡូត៍" ០០